អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦

# សេចក្តីប្រកាសព័ត៌មាន

## អង្គជំនុំជម្រះតុលាការកំពូលបដិសេធចោលការដាក់ពិរុទ្ធភាព មួយចំនួន និងតម្កល់ការផ្តន្ទាទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត សម្រាប់ នួន ជា និង ខៀវ សំផន នៅក្នុងសំណុំរឿង ០០២/០១

នៅថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានប្រកាសសាលដីការបស់ខ្លួនលើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង ០០២/០១ ប្រឆាំងនឹង នួន ជា អតីតអនុលេខាបក្សកុម្មុយនីស្តកម្ពុជា និង ខៀវ សំផន អតីតប្រមុខរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ។

អង្គជំនុំជម្រះតុលាការកំពូលបានតម្កល់ការផ្តន្ទាទោសទៅលើ នួន ជា និង ខៀវ សំផន ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការធ្វើមនុស្សឃាត ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ទាក់ទិននឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ភ្លាមៗបន្ទាប់ពីការដួលរលំទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែ មេសា ឆ្នាំ ១៩៧៥។ ទាក់ទិនទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២ ដែលបានកើតឡើងនៅចន្លោះឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៧ អង្គជំនុំជម្រះបានតម្កល់ការផ្តន្ទាទោសជនជាប់ចោទចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងៗទៀត និងបានផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើមនុស្សឃាត។

អង្គជំនុំជម្រះតុលាការកំពូលបានច្រានចោលការដាក់ពិរុទ្ធភាពដែលបានសម្រេចដោយអង្គជំនុំជម្រះសាលាដំបូង ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាការសម្លាប់រង្គាល ទាក់ទិននឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ទាក់ទិននឹងការផ្លាស់ទីលំនៅប្រជាជន មិនបានបង្ហាញដោយលើសពីវិមតិសង្ស័យថា ការសម្លាប់ជាទ្រង់ទ្រាយធំ ដែលជាធាតុផ្សំចាំបាច់ ត្រូវបានប្រព្រឹត្តឡើងដោយមានចេតនាផ្ទាល់នោះឡើយ។

ទាក់ទិននឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២ អង្គជំនុំជម្រះតុលាការកំពូលក៏បានច្រានចោលការដាក់ពិរុទ្ធភាពរបស់អង្គជំនុំជម្រះសាលាដំបូងផងដែរ ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ដោយបានសន្និដ្ឋានថា ភ័ស្តុតាងមិនបានបង្ហាញថា ភាគច្រើនលើសលប់នៃប្រជាជនដែលត្រូវបានជម្លៀសនោះ ជា "ប្រជាជនថ្មី" ឡើយ។ ដូច្នេះ មិនមានការបង្ហាញថា ការផ្លាស់ទីលំនៅប្រជាជន មានលក្ខណៈរើសអើងជាក់ស្តែងនោះទេ។

ទោះបីជាអង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា យ៉ាងហោចណាស់ទាហាន និងអ្នករដ្ឋការ លន់ នល់ ចំនួន ២៥០ នាក់ ត្រូវបានសម្លាប់នៅទួលពោធិ៍ជ្រៃ នៅចុងខែ មេសា ឆ្នាំ ១៩៧៥ ដូច្នេះហើយ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទំនងជាត្រូវបានប្រព្រឹត្តឡើងក៏ដោយ ក៏ភ័ស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងមិនគ្រប់គ្រាន់ដើម្បីគាំទ្រយ៉ាងសមហេតុផលដល់ការសន្និដ្ឋានថា នៅក្នុងព្រឹត្តិការណ៍ទាំងនោះ មានគោលនយោបាយក្នុងការសម្លាប់ទាហាន លន់ នល់ នោះឡើយ។ ភ័ស្តុតាងភាគច្រើនរួមមាន ចម្លើយដែលបានធ្វើឡើងនៅក្រៅតុលាការ ដែលមានតម្លៃជាភ័ស្តុតាងតិចតួច។ លើសពីនេះទៀត អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានពិចារណាទៅលើភ័ស្តុតាងមួយចំនួន ដែលធ្វើឲ្យមានមន្ទិលចំពោះអត្ថិភាពនៃគោលនយោបាយសម្លាប់ជាទូទៅនេះ។ អាស្រ័យហេតុនេះ ព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃមិនអាចទម្លាក់ការទទួលខុសត្រូវទៅលើជនជាប់ចោទឡើយ ដូច្នេះហើយ ពួកគាត់មិនអាចដាក់ឲ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះព្រឹត្តិការណ៍ទាំងនោះទេ។ ផ្អែកលើហេតុផលនេះ អង្គជំនុំជម្រះតុលាការកំពូលបានច្រានចោលការការដាក់ពិរុទ្ធភាព នួន ជា និង ខៀវ សំផន ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយនៅទួលពោធិ៍ជ្រៃ។

អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាថាតើ ការដែលអង្គជំនុំជម្រះតុលាការកំពូលបានរកឃើញកំហុសនៅក្នុងសេចក្តីសន្និដ្ឋានមួយចំនួនរបស់អង្គជំនុំជម្រះសាលាដំបូងនោះ គួរតែតម្រូវឲ្យអង្គជំនុំជម្រះតុលាការកំពូលកែតម្រូវការដាក់ទោសដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចដែរទេ។ ដោយហេតុថា ការផ្តន្ទាទោសគួរតែឆ្លុះបញ្ចាំងអំពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម ដោយពិចារណាទៅលើទ្រង់ទ្រាយធំនៃឧក្រិដ្ឋកម្ម ការខកខានមិនបានពិចារណាចំពោះជោគវាសនាចុងក្រោយរបស់ប្រជាជនកម្ពុជា ជាពិសេស ក្រុមដែលងាយទទួលរងផលប៉ះពាល់បំផុត អង្គហេតុដែលថាឧក្រិដ្ឋកម្មទាំងនោះមិនមែនជាព្រឹត្តិការណ៍ដាច់ដោយឡែកពីគ្នា ប៉ុន្តែឧក្រិដ្ឋកម្មទាំងនោះបានកើតឡើងនៅក្នុងរយៈពេលយូរមួយ និងតួនាទីយ៉ាងសំខាន់របស់ជនជាប់ចោទនោះ អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា ការដាក់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិតដល់ជនជាប់ចោទនីមួយៗនោះ គឺជាការសមស្រប ដូច្នេះហើយ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចតម្កល់ការដាក់ទោសរបស់អង្គជំនុំជម្រះសាលាដំបូងនេះ។

ផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ប្រអប់សំបុត្រ ៧១ ភ្នំពេញ កម្ពុជា ទូរស័ព្ទ (៨៥៥) ០២៣ ៨៦១ ៥០០ ទូរសារ (៨៥៥) ០២៣ ៨៦១៥៥៥ គេហទំព័រ
www.eccc.gov.kh
National Road 4, Chaom Chao, Porsenchey, P.O. Box 71, Phnom Penh Cambodia Tel: (855) 023 861 500 Fax :(855) 023 861 555
www.eccc.gov.kh

អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ដែលស្នើសុំតែការបំភ្លឺទៅលើការអនុវត្តទម្រង់ទូលាយបំផុតនៃសហឧក្រិដ្ឋកម្មរួម (JCE) នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានោះ មិនអាចទទួលយកបានទេ។ ទោះបីជាយ៉ាងណាក៏ដោយ បណ្ដឹងសាទុក្ខរបស់ជនជាប់ចោទបានប្ដឹងមកអង្គជំនុំជម្រះតុលាការកំពូលអំពីបញ្ហានានាពាក់ព័ន្ធនឹងសញ្ញាណនៃសហឧក្រិដ្ឋកម្មរួម រួមទាំងបញ្ហានានាដែលបានលើកឡើងនៅក្នុងបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖


លោក ឡាស អូលសិន
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
**ទូរស័ព្ទចល័ត:** +855 (0)12 488 023
**ទូរសព្ទលើតុ:** +855 (0)23 861 669
**សារអេឡិចត្រូនិក:** olsenl@un.org

លោក នេត្រ ភក្ត្រា
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
**ទូរសព្ទចល័ត:** +855 (0)12 488 156
**ទូរសព្ទលើតុ:** +855 (0)23 861 564
**សារអេឡិចត្រូនិក:** neth.phektra@eccc.gov.kh